

# បទអន្តរាគមន៍

# ស្តីពី

# ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល

# របស់រដ្ឋបាលស្រុកទឹកឈូ

**បង្ហាញដោយលោក អ៊ឹម ច័ន្ទសោធន អភិបាលស្រុក**

**ទឹកឈូ, ថ្ងៃទី ....... ខែ កញ្ញា ឆ្នាំ២០២៤**

# មាតិកា

១. សាវតា

២. ភូមិសាស្ត្រ និងប្រជាសាស្ត្រ

៣.ក្របខណ្ឌគតិយុត្តិ

៤.ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល

៥.បញ្ហាប្រឈម  និងសំណូមពរ

៦. ទិសដៅអនុវត្តបន្ត

៧.សេចក្តីសន្និដ្ឋាន

# ១. សាវតា

- បន្ទាប់ពីទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ការឯកភាពទឹកដីដ៏ពេញលេញនាចុងទស្សវត្ស៩០ តាមរយៈការអនុវត្តគោលនយោបាយ"ឈ្នះ ឈ្នះ" រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញឲ្យអនុវត្តនូវគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់លើគ្រប់វិស័យដើម្បីធានាដល់ការបន្តថែរក្សាឲ្យបានគង់វង្សនូវសន្តិភាព ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមឲ្យមានភាពរុងរឿង សម្បូរណ៍សប្បាយប្រកបដោយបរិយាប័ន្ន និងសមធ៌ម។
- ជំហានដំបូងចាប់ផ្តើមការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ដែលជារដ្ឋបាលមួយនៅកៀកកិតប្រជាពលរដ្ឋ។ ហេតុនេះទើបឆ្នាំ២០០២ មានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ទូទាំងប្រទេស។
- បន្ទាប់ពីភាពជោគជ័យនៃការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ ក្នុងឆ្នាំ២០០៩ រាជរដ្ឋាភិបាលកម្ពុជា បានពង្រីកការអនុវត្តកំណែទម្រង់នេះទៅថ្នាក់រដ្ឋបាលក្រោមជាតិផ្សេងទៀតទូទាំងប្រទេសតាមរយៈដំណើរការបោះឆ្នោតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ តាមរយៈកំណែទម្រង់នេះ សិទ្ធិ អំណាច ការទទួលខុសត្រូវ មុខងារ និងធនធាន ត្រូវបានផ្ទេរជាបន្តបន្ទាប់ពីថ្នាក់ជាតិ ទៅថ្នាក់ក្រោមជាតិ។
- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការផ្តោតលើការរៀបចំនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសារធារណៈនៅថ្នាក់ក្រោមជាតិ។ មានគោលបំណងគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធិភាព ឆ្លើយតប និងមានគណនេយ្យភាព។

# ២. ភូមិសាស្ត្រ និងប្រជាសាស្ត្រ



# ២. ភូមិសាស្ត្រ និងប្រជាសាស្ត្រ (ត)

ស្រុកទឹកឈូ ជាស្រុកមួយក្នុងចំណោមស្រុក/ក្រុងទាំង៩ នៃខេត្តកំពត  ដែលមានព្រំប្រទល់

-ខាងជើងជាប់ស្រុកដងទង់ និងស្រុកឈូក នៃខេត្តកំពត

-ខាងត្បូងជាប់នឹងខេត្តកែប និងដែនសមុទ្រ

-ខាងកើតជាប់នឹងខេត្តកែប និងស្រុកដងទង់នៃខេត្តកំពត

-ខាងលិចជាប់នឹងក្រុងកំពត និងក្រុងបូកគោនៃខេត្តកំពត

-ចែកចេញជា១៣ ឃុំ ៥៥ ភូមិ ហើយមានផ្ទៃដីសរុប ១,៣៦១.៧០ គីឡូម៉ែត្រការ៉េ គ្រួសារប្រជាពលរដ្ឋសរុប ២៣,៣៤៩ គ្រួសារ   មនុស្សសរុប ១០១,៩២០ នាក់ ស្រី ៥២,៥៣០នាក់   អាយុ១៨ ឆ្នាំឡើង ៦៥,៨៨៩នាក់  ស្រី ៣៤,៧៦៩នាក់។

# ៣. ក្របខណ្ឌគតិយុត្តិ

❖ ដំណើរការអនុវត្តជាជំហានៗ នូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាមានដូចជា៖

- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ ទី២ ទី៣ និងទី៤ និងបន្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នីតិកាលទី៧ នៃរដ្ឋសភា

- ក្របខណ្ឌយុត្តិសាស្ត្រ ស្ដីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- ច្បាប់ស្ដីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ៣. ក្របខណ្ឌគតិយុត្តិ (ត)

-កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី១ និង ដំណាក់កាលទី២

- អនុក្រឹត្យ១៨៤ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ស្តីពីមុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- អនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

# ៣. ក្របខ័ណ្ឌគតិយុត្ត(ត)

- អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី០៥ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

- អនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២៣ ស្តីពីការផ្ទេរមុខងារ ក្នុងវិស័យអប់រំយុវជន និងកីឡាទៅឲ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ











ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥៤ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**មុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃ ទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

១/២៥

# ៤. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល





- ❖ តាមរយៈលទ្ធផលនៃកំណែទម្រង់នេះ មុខងារ និងធនធាន ត្រូវបានផ្ទេរដល់រដ្ឋបាលស្រុកជាបន្តបន្ទាប់ ដែលធ្វើឲ្យស្រុកមានលទ្ធភាពក្នុងការចាត់ចែង និងធ្វើការសម្រេចចិត្តក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋកាន់តែមានប្រសិទ្ធិភាពជាងមុន។
- ❖ ជាក់ស្តែងដោយមើលឃើញពីការលំបាករបស់ប្រជាពលរដ្ឋក្នុងការមកទទួលសេវាអត្រានុកូលដ្ឋាន និងដើម្បីផ្តល់ភាពងាយស្រួលដល់មន្ត្រីក្នុងការរក្សា និងផ្ទៀងផ្ទាត់សៀវភៅគល់បញ្ជីដដែលៗ រដ្ឋបាលស្រុកដោយមានការគាំទ្រនិងលើកទឹកចិត្តពីរដ្ឋបាលខេត្តនៅដើមឆ្នាំ២០២៣បានផ្តួចផ្តើមផ្សព្វផ្សាយដាក់អោយប្រើប្រាស់កម្មវិធីស្នើសុំសេវាអត្រានុកូលដ្ឋានតាមរយៈអនឡាញ។

- ដោយមានការគាំទ្រពីសាធារណៈជនចំពោះការស្នើសុំចម្លងអត្រានុកូលដ្ឋានដែលបានប្រើប្រាស់តាមអនឡាញ រដ្ឋបាលស្រុកបានបន្តបង្កើត WEB APPLICATION សម្រាប់គ្រប់គ្រងទិន្នន័យអត្រានុកូលដ្ឋានគ្រប់ប្រភេទ (ចាប់ពីឆ្នាំ ២០០២ ដល់បច្ចុប្បន្ន) និងបានដាក់អោយប្រើប្រាស់កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ ហើយគ្រោងនឹងបញ្ចប់ការបញ្ចូលទិន្នន័យនាចុងឆ្នាំនេះ។មិនតែប៉ុណ្ណោះ WEB APPLICATION ក៏ត្រូវបានដាក់ឲ្យប្រើប្រាស់នៅថ្នាក់ឃុំក្នុងការបញ្ចូលទិន្នន័យក្នុងឆ្នាំអនុវត្តផងដែរ។





# ៤. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល(ត)

- ដោយមើលឃើញពីភាពចាំបាច់ក្នុងការងារ បន្ថែមពីអ្វីដែលកំពុងដំណើរការក្នុងពេលបច្ចុប្បន្ន រដ្ឋបាលស្រុកបានបង្កើត វែបសាយ និងត្រៀមដាក់ដំណើរការក្នុងត្រីមាសទី៣នេះ។តាមរយៈនេះនឹងបើកទូលាយជូនប្រជាពលរដ្ឋក្នុងការស្នើសុំសេវា ការចូលមើលទិន្នន័យបញ្ជីអត្រានុកូលដ្ឋានរបស់ខ្លួនការផ្សព្វផ្សាយអំពីសកម្មភាព និងសមិទ្ធិផលនានា ការផ្សព្វផ្សាយពីតំបន់ទេសចរណ៍ក្នុងស្រុក ការផ្សព្វផ្សាយពីផលិតផលភូមិ១ ផលិតផល ១ និងមុខងារពាក់ព័ន្ធផ្សេងៗទៀតដែលនឹងអភិវឌ្ឍន៍បន្ថែមបន្ទាប់ពីដំណើរការ សំដៅធ្វើឲ្យការផ្តល់សេវាកាន់តែមានគុណភាព និងមានលក្ខណៈនវានុវត្តន៍។



# បណ្តាញទំនាក់ទំនងសង្គម
# របស់រដ្ឋបាលស្រុកសម្រាប់ទទួលការស្នើសុំសេវាពីប្រជាពលរដ្ឋ






# បណ្តាញទំនាក់ទំនងសង្គម
# របស់រដ្ឋបាលស្រុកសម្រាប់ការទទួលការស្នើសុំសេវាពីប្រជាពលរដ្ឋ






# កម្មវិធីផ្តល់សេវា និង រក្សាទុកទិន្នន័យ



# វេបសាយរដ្ឋបាលស្រុកទឹកឈូ






❖ ក្រៅពីការប្រើប្រាស់សេវាអនឡាញដោយផ្ដួចផ្ដើមដោយរដ្ឋបាលស្រុកផ្ទាល់ ក៏បាន និងកំពុងប្រើប្រាស់នូវប្រព័ន្ធទំនាក់ទំនងតាមបែបឌីជីថលរបស់ថ្នាក់ជាតិសម្រាប់គ្រប់គ្រងទិន្នន័យការងារជាជំហានៗតាមរយៈ ONLINE មានដូចជា

- ➢ ប្រព័ន្ធទិន្នន័យសម្រាប់គ្រប់គ្រងកិច្ចបញ្ជីការហិរញ្ញវត្ថុ(FMIS PORTAL)
- ➢ កម្មវិធីគ្រប់គ្រងទិន្នន័យការិយាល័យច្រកចេញចូលតែមួយ(DMK.OWSO.GOV.KH)
- ➢ ប្រព័ន្ធបច្ចេកវិទ្យាពត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ( NRMIS.MES.GOV.KH)
- ➢ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ(SAMIS)
- ➢ ទិន្នន័យសម្រាប់ការរាយការណ៍គ្រោះមហន្តរាយ(PRISME)
- ➢ ការផ្ដល់សេវាក្នុងវិស័យសាធារណៈការ(GDTSYS.MPWT.GOV.KH)

# ៤. ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល(ត)

❖ **ចំនុចខ្លាំង**

- ផ្សព្វផ្សាយព័ត៌មាននានាជាប្រចាំទៅកាន់សាធារណៈជនតាមរយៈបណ្តាញទំនាក់ទំនងសង្គម ការបិទផ្សាយនៅបញ្ជរក្តារព័តមានស្រុក និងការវេទិកាសាធារណៈនៅតាមភូមិ ឃុំ
- បង្កើតផេករដ្ឋបាលស្រុក ដើម្បីផ្សព្វផ្សាយសកម្មភាព និងលទ្ធផលការងាររបស់រដ្ឋបាលស្រុក  ទទួលសំណើ មតិប្រជាពលរដ្ឋ និងប្រើប្រាស់ក្នុងស្នើសុំសេវាលើវិស័យអត្រានុកូលដ្ឋាន។
- សហការជាមួយអង្គការតម្លាភាពដាក់ឲ្យប្រើប្រាស់APP **មតិយើង** ដើម្បីទទួលនូវមតិ យោបល់ និង បញ្ហានានា
- ដាក់ប្រអប់សំបុត្រផ្តល់មតិទូទាំង១៣ឃុំ និងទីប្រជុំជនស្រុក
- បង្កើតក្រុមការងាររដ្ឋបាលគាំទ្រ
- មានភាពច្នៃប្រឌិតលើធនធានដែលមាន

# ៥. បញ្ហាប្រឈម និងសំណូមពរ

១. មិនទាន់មានសេចក្តីណែនាំពាក់ព័ន្ធសមត្ថកិច្ចនៃការកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានតាមច្បាប់ថ្មី។ ការស្នើសុំកែតម្រូវទិន្នន័យអត្រានុកូលដ្ឋានកន្លងមកមានភាពស្មុគស្មាញ និងចំណាយពេលវេលាយូរ។ បាត់សៀវភៅគល់បញ្ជី ឬកោសលុបឯកសារខុសពីការណែនាំតម្រូវឲ្យមានការផ្ទៀងផ្ទាត់គល់បញ្ជីនៅក្រសួង។

២. ធនធានមនុស្សមិនគ្រប់គ្រាន់ មន្ត្រីចូលនិវត្តន៍ច្រើន មន្ត្រីកិច្ចសន្យាមានចំនួនតិច ។

៣. ការគាំទ្រពីអង្គភាពពាក់ព័ន្ធ លើការបណ្តុះបណ្តាលបង្កើនសមត្ថភាពមន្ត្រីនៅមានកម្រិត

# ៦. ទិសដៅអនុវត្តបន្ត

- បន្តការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព ប្រសិទ្ធិភាព និងទាន់ពេលវេលា
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីឲ្យក្លាយជាមន្ត្រីប្រកបដោយគុណវុឌ្ឍិ
- យកចិត្តទុកដាក់លើតួនាទី ភារៈកិច្ច របស់ការិយាល័យច្រកចេញចូលតែមួយ
- ពង្រឹង និងពង្រីកការផ្តល់សេវា និងការគ្រប់គ្រងទិន្នន័យតាមអនឡាញ
- អភិវឌ្ឍ និងដាក់ឲ្យដំណើរការវេបសាយសម្រាប់ប្រជាពលរដ្ឋចូលទៅស្នើសុំសេវាសេចក្តីចម្លងអត្រានុកូលដ្ឋាន ព្រមទាំងការចូលមើលព័ត៌មានចាំបាច់នានារបស់រដ្ឋបាលស្រុក។



# សេចក្តីសន្និដ្ឋាន

តាមរយៈនៃការអនុវត្តកំណែទម្រង់ជាជំហានៗ រដ្ឋបាលស្រុកមានសមត្ថភាព និងលទ្ធភាពពេញលេញក្នុងការបំពេញមុខងារ និងផ្តល់សេវាជូនប្រជាពលរដ្ឋកាន់តែមានប្រសិទ្ធិភាព និងប្រសិទ្ធិផល គួរជាទីមោទនៈ។ មិនតែប៉ុណ្ណោះ រដ្ឋបាលស្រុកបានអភិវឌ្ឍន៍ខ្លួនដោយអនុលោមតាមច្បាប់ គោលនយោបាយ កម្មវិធីជាតិ យន្តការនីតិវិធីនានា ឲ្យសក្តិសមជារដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈនិងការដោះស្រាយបញ្ហាប្រឈមនានាក្នុងដែនសមត្ថកិច្ចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។


សូមអរគុណ